# សេចក្តីប្រកាសព័ត៌មាន

នៅរសៀលថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០២១ នៅអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ **សម្តេចពិជ័យសេនា ឧបនាយក-រដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ** និងឯកឧត្តម **វ៉ាង វិន ជាន** ឯកអគ្គរដ្ឋទូតចិនប្រចាំកម្ពុជា បានអញ្ជើញជាអធិបតីក្នុង **"ពិធីប្រគល់-ទទួលសម្ភារៈវេជ្ជសាស្ត្រដ៏ថ្លៃថ្លាពីក្រសួងការពារជាតិ នៃសាធារណរដ្ឋប្រជាមានិតចិន ជូនក្រសួងការពារជាតិ នៃព្រះរាជាណាចក្រកម្ពុជា ដើម្បីទប់ស្កាត់ការរីករាលដាលជំងឺកូវីដ-១៩"**។

**សម្តេចពិជ័យសេនា** បានថ្លែងអំណរគុណចំពោះប្រជាជន រដ្ឋាភិបាល និងកងទ័ពរំដោះប្រជាជនចិន ដែលបានផ្តល់សម្ភារៈវេជ្ជសាស្ត្រ ជូនកងយោធពលខេមរភូមិន្ទ រួមចំណែកយ៉ាងសំខាន់ក្នុងយុទ្ធនាការប្រយុទ្ធប្រឆាំងការរីករាលដាលនៃជំងឺកូវីដ-១៩នៅកម្ពុជា ក្នុងស្មារតីមិត្តភាព និងសាមគ្គីភាពដូចពាក្យស្លោកពោលថា **"មិត្តល្អជួយគ្នាក្នុងគ្រាមានអាសន្ន"** និងជាមិត្តដែកថែបដ៏ពិតប្រាកដ តែងតែជួយគាំទ្រដល់ប្រជាជន កងទ័ពកម្ពុជាគ្រប់គ្រាលំបាកទាន់ពេលវេលា និងគ្មានលក្ខខណ្ឌ ក្នុងស្មារតីទំនាក់ទំនងមិត្តភាពជាប្រពៃណីដ៏ល្អប្រសើរ និងពង្រឹងកិច្ចទំនាក់ទំនងដ៏ស៊ីជម្រៅកាន់តែរឹងមាំលើគ្រប់វិស័យ។

**សម្តេចពិជ័យសេនា** បញ្ជាក់បន្ថែមថា ការទទួលសម្ភារៈវេជ្ជសាស្ត្រពីក្រសួងការពារជាតិចិននាពេលនេះ គឺជាជំនួយបន្ថែមពីលើការផ្តល់វ៉ាក់សាំងបង្ការជំងឺកូវីដ-១៩ និងការបញ្ជូនក្រុមវេជ្ជសាស្ត្រយោធាមកកម្ពុជា ដើម្បីផ្តល់បទពិសោធន៍ និងរួមសហការគ្នាប្រយុទ្ធនឹងជំងឺកូវីដ-១៩នាពេលកន្លងមក បានរួមចំណែកក្នុងការអនុវត្តយុទ្ធសាស្ត្រស្នូល ដែលជាគន្លឹះក្នុងការការពារសុខភាពសាធារណៈ និងជួយសង្គ្រោះអាយុជីវិតប្រជាជនកម្ពុជា។ ជំនួយទាំងអស់នេះ នឹងបង្កើនសមត្ថភាពដល់កងយោធពលខេមរភូមិន្ទ ឲ្យកាន់តែប្រសើរឡើងថែមទៀត ក្នុងការលើកកម្ពស់កម្រិតជំនាញបច្ចេកទេសការស្រាវជ្រាវរកមេរោគកូវីដ-១៩, យកសំណាក, ធ្វើតេស្តរកមេរោគ និងព្យាបាលជំងឺកូវីដ-១៩។

**សម្តេចពិជ័យសេនា** បានគូសបញ្ជាក់បន្ថែមថា នៅក្នុងបរិបទនៃការរីករាលដាលជំងឺកូវីដ-១៩ រយៈពេលជិតពីរឆ្នាំមកនេះ រាជរដ្ឋាភិបាលកម្ពុជាក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតរបស់**សម្តេចតេជោ នាយករដ្ឋមន្ត្រី** បានកំណត់យកការចាក់វ៉ាក់សាំងជាវិធានការគន្លឹះ បន្ថែមលើវិធានការសំខាន់ៗដទៃទៀត ដើម្បីទប់ស្កាត់ការឆ្លងរីករាលដាលនៃជំងឺកូវីដ-១៩ សំដៅការពារសុខភាពសាធារណៈ និងជួយសង្គ្រោះអាយុជីវិតប្រជាជន។ រាជរដ្ឋាភិបាលកម្ពុជាបានចាត់ទុកវ៉ាក់សាំង និងសម្ភារៈវេជ្ជសាស្ត្រជាទំនិញយុទ្ធសាស្ត្រ និងបានដាក់ចេញយុទ្ធសាស្ត្រទិញឲ្យបានគ្រប់គ្រាន់ និងឆាប់បំផុត ដើម្បីចាក់វ៉ាក់សាំងជូនប្រជាពលរដ្ឋនៅទូទាំងប្រទេស ដោយចាប់ផ្តើមពីមន្ត្រី និងកងកម្លាំងបម្រើសេវាជួរមុខ បន្ទាប់មកប្រជាជនដែលមានអាយុចាប់ពី១៨ឆ្នាំឡើង កុមារនិងយុវវ័យដែលមានអាយុចាប់ពី៦ឆ្នាំ ដល់ក្រោម១៨ឆ្នាំ និងចុងក្រោយនេះកុមារដែលមានអាយុ៥ឆ្នាំ។

រាជរដ្ឋាភិបាលកម្ពុជាទទួលបានជោគជ័យក្នុងការដាក់ចេញយុទ្ធសាស្ត្រនេះបានត្រឹមត្រូវ ច្បាស់លាស់ ទាន់ពេលវេលា និងជ្រើសរើសមិត្តចិនជាបង្អែកយុទ្ធសាស្ត្រសម្រាប់ការផ្គត់ផ្គង់វ៉ាក់សាំង រួមជាមួយដៃគូផ្សេងទៀត ធ្វើឲ្យកម្ពុជាទទួលបានបរិមាណវ៉ាក់សាំងគ្រប់គ្រាន់ សម្រាប់យុទ្ធនាការជាតិចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ-១៩។ លទ្ធផលនេះ បានផ្តល់លទ្ធភាពឲ្យកម្ពុជា សម្រេច ជោគជ័យមុនផែនការកំណត់នូវយុទ្ធនាការជាតិចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ-១៩ និងបានប្រកាសជាផ្លូវការបើកប្រទេសដំណើរការឡើងវិញលើគ្រប់វិស័យជាបណ្តើរៗ សំដៅស្តារ និងជំរុញកំណើនសេដ្ឋកិច្ចតាមគន្លងប្រក្រតីភាពថ្មី កាលពីថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០២១។

**សម្តេចពិជ័យសេនា** បានធ្វើការវាយតម្លៃថា ការអនុវត្តយុទ្ធនាការចាក់វ៉ាក់សាំងបានទាន់ពេលវេលានេះ ធ្វើឲ្យកម្ពុជាក្លាយជាប្រទេសមួយក្នុងចំណោមបណ្តាប្រទេស ដែលមានអត្រាគ្របដណ្តប់នៃការចាក់វ៉ាក់សាំងខ្ពស់ជាងគេ ទាំងក្នុងតំបន់ និងសកលលោក សម្រេចបាននូវភាពស៊ាំសហគមន៍រឹងមាំពិតប្រាកដមួយ បានរួមចំណែកកាត់បន្ថយការឆ្លងរាលដាល ការចម្លង ការវិវត្តទៅរកភាពធ្ងន់ធ្ងរនៃជំងឺ និងអត្រាមរណភាព ជានាបាននូវការរស់នៅតាមគន្លងប្រក្រតីភាពថ្មី ព្រមទាំងស្តារ

និងជំរុញឡើងវិញនូវកំណើនសេដ្ឋកិច្ច និងវឌ្ឍនភាពសង្គម។ ភាពជោគជ័យ នៃការអនុវត្តយុទ្ធនាការជាតិចាក់វ៉ាក់សាំងជូនប្រជាជននាពេលកន្លងមក បានបញ្ជាក់ច្បាស់ថា វត្តមានកងយោធពលខេមរភូមិន្ទ បានរួមចំណែកយ៉ាងសំខាន់ក្នុងកិច្ចដំណើរការចាក់វ៉ាក់សាំងនេះ ហើយជោគជ័យទាំងអស់នេះ មិនអាចខ្វះបាននូវការជួយគាំទ្រឧបត្ថម្ភទាំងវ៉ាក់សាំង សម្ភារៈវេជ្ជសាស្ត្រ ក្រុមវេជ្ជសាស្ត្រ និងបទពិសោធន៍ពីសំណាក់ប្រជាជន រដ្ឋាភិបាល ពិសេសកងទ័ពរំដោះប្រជាជនចិនចំពោះកងយោធពលខេមរភូមិន្ទបានឡើយ។

**សម្តេចពិជ័យសេនា** បានថ្លែងអំណរគុណចំពោះមិត្តចិន ដែលបានចូលរួមយ៉ាងសកម្មក្នុងបុព្វហេតុមនុស្សជាតិ នៃការប្រយុទ្ធនឹងជំងឺកូវីដ-១៩ និងតែងតែគាំទ្រលើកកម្ពស់សមត្ថភាពបច្ចេកទេសលើគ្រប់វិស័យ ដល់កងយោធពលខេមរ-ភូមិន្ទ រួមចំណែកក្នុងដំណើរការអភិវឌ្ឍសង្គម សេដ្ឋកិច្ចកម្ពុជានាពេលកន្លងមក។ អរគុណចំពោះឯកឧត្តម ឯកអគ្គរដ្ឋទូត **វ៉ាង វិន ធាន** និងនាយទាហានការិយាល័យអនុព័ន្ធយោធាប្រចាំកម្ពុជា ចំពោះការជួយសម្របសម្រួលការងារគ្រប់បែបយ៉ាងជូនក្រសួងការពារជាតិបានទាន់ពេលវេលា។

នៅក្នុងពិធីនេះ ឯកឧត្តម ឯកអគ្គរដ្ឋទូត **វ៉ាង វិន ធាន** បានបញ្ជាក់ជូនថា កងទ័ពប្រទេសទាំងពីរកម្ពុជា-ចិន ជាបងប្អូនគឺជាមិត្តដែកថែប ស្គាល់ចិត្តគ្នា ជួយគ្នាទៅវិញទៅមក មានចំណងមិត្តភាពប្រៀបដូចដៃ និងជើង។ នៅក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ រដ្ឋាភិបាលក្រោមការដឹកនាំដោយផ្ទាល់ និងជំរុញយ៉ាងពេញទំហឹងពីឯកឧត្តម ប្រធានាធិបតីចិន **ស៊ី ជីង ពីង** និង**សម្តេចតេជោ នាយករដ្ឋមន្ត្រី** ធ្វើឲ្យកងទ័ពប្រទេសទាំងពីរពង្រឹងកិច្ចសហប្រតិបត្តិការ បោះជំហានមានការរីកចម្រើនលើគ្រប់វិស័យ។

ឯកឧត្តម ឯកអគ្គរដ្ឋទូត **វ៉ាង វិន ធាន** បានបញ្ជាក់បន្ថែមថា ក្រោយពីមានការកើតឡើងនូវជំងឺកូវីដ-១៩ ប្រជាជនកងទ័ពប្រទេសទាំងពីរតែងតែជួយគ្នាទៅវិញទៅមក និងបានផ្តល់អំណោយជាថ្នាំពេទ្យ សម្ភារៈវេជ្ជសាស្ត្រ ដើម្បីទប់ស្កាត់ការរីករាលដាលជំងឺកូវីដ-១៩។ កិច្ចសហប្រតិបត្តិការនេះ មិនត្រឹមបង្កើតបានជាគម្រូនៃកិច្ចសហប្រតិបត្តិការយោធាអន្តរជាតិប៉ុណ្ណោះទេ ប៉ុន្តែបានរួមចំណែកយ៉ាងសំខាន់ក្នុងកិច្ចកសាងសហគមន៍ វាសនារួមរវាងចិននិងកម្ពុជា។

**សម្តេចពិជ័យសេនា** និងឯកឧត្តម ឯកអគ្គរដ្ឋទូត **វ៉ាង វិន ធាន** បានប្តេជ្ញាចិត្តរួមគ្នាខិតខំជំរុញកិច្ចសហប្រតិបត្តិការលើកកម្ពស់ទំនាក់ទំនងភាពជាដៃគូយុទ្ធសាស្ត្រគ្រប់ជ្រុងជ្រោយ រវាងកងយោធពលខេមរភូមិន្ទ ជាមួយកងទ័ពរំដោះប្រជា-ជនចិនឲ្យកាន់តែស៊ីជម្រៅ រួមចំណែកផ្តល់អត្ថប្រយោជន៍ជូនប្រជាជនប្រទេសទាំងពីរកម្ពុជា-ចិន ឲ្យកាន់តែមានភាពរីកចម្រើនថែមទៀត។